00286617

D130/2

**នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

| | |
|---|---|
| **សំណុំរឿងលេខ:** | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក-ស.ច.ស |
| **បញ្ជូនទៅ:** | សហចៅក្រមស៊ើបអង្កេត |
| **កាលបរិច្ឆេទនៃការបញ្ជូន** | ថ្ងៃទី ៦ ខែមិនា ឆ្នាំ២០០៩ |
| **ភាគីបញ្ជូន:** | **មេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ** |
| **ភាសាដើម:** | អង់គ្លេស និង ខ្មែរ (អត្ថបទបកប្រែ) |
| **ប្រភេទឯកសារ:** | សាធារណៈ |

**ឯកសារដើម**
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 06 / 03 / 2009
ម៉ោង (Time/Heure): 14:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**ចម្លើយតបរបស់មេធាវីការពារក្តីចំពោះសំណើរបស់ ក.ស.ព ស្នើសុំបង្កើនចំនួនសន្លឹកកំណត់ ដើម្បីដាក់ចម្លើយតបរបស់ខ្លួនទៅនឹងពាក្យសុំច្រានចោលភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម**

<u>បញ្ជូនដោយ៖</u>

**សហមេធាវីការពារអ្នកស្រី អៀង ធីរិទ្ធ**
លោកមេធាវី ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Robert PETIT

**ឯកសារបានចម្លងត្រឹមត្រូវតាមច្បាប់ដើម**
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 10 / MAR / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. Fry

<u>អ្នកទទួលឯកសារ:</u>

**សហចៅក្រមស៊ើបអង្កេត**
លោក យូ ប៊ុនឡេង
លោក Marcel Lemond

**មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី៖**
លោក ហុង គីមសួន
លោក ឡោ ជុនធី
លោក នី ចាន់ឌី
លោក គង់ ពិសី
Silke Studzinsky
លោក យ៉ុង ផានីត
លោក គីម ម៉េងឃី
Martine JACQUIN
Phillipe CANNONE
Pierre Olivier SUR
Elizabeth RABESANRATANA
Olivier BAHOUGNE
David BLACKMAN

## I. សេចក្ដីផ្ដើម

1. នៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ២០០៩ មេធាវីការពារក្ដីអ្នកស្រី អៀង ធិរិទ្ធ បានដាក់ "សំណើរបស់ខ្លួនស្នើសុំច្រានចោលភស្ដុតាងដែលបានមកពីការធ្វើទារុណកម្ម" (ហៅថា "**សំណើសុំច្រានចោលភស្ដុតាង**"[1] ។

2. ការិយាល័យសហព្រះរាជអាជ្ញា (ហៅថា "ក.ស.ព") នៅថ្ងៃទី៣ ខែ មិនា ឆ្នាំ ២០០៩ បានដាក់ " សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំបង្កើនចំនួនសន្លឹកកំណត់ ដើម្បីដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសំណើរបស់អ្នកស្រី អៀង ធិរិទ្ធ ស្នើសុំច្រានចោលភស្ដុតាងដែលបានមកពីការធ្វើទារុណកម្ម"[2] (ហៅថា "**សំណើរបស់ ក.ស.ព**" ដែលក្នុងសំណើនោះ ក.ស.ព បានស្នើសុំការិយាល័យសហចៅក្រមស៊ើបអង្កេត (ហៅថា "ក.ស.ច.ស") ឲ្យបង្កើនចំនួនសន្លឹកកំណត់សម្រាប់ចម្លើយតបដែលខ្លួនមានបំណងដាក់ រហូតដល់ចំនួន ៣០ សន្លឹកឯណោះ ដោយសារតែជា"កាលៈទេសៈពិសេស"។

3. មេធាវីការពារក្ដីសូមជំទាស់ទៅនឹងសំណើរបស់ ក.ស.ព ដោយសារតែជាកាលៈទេសៈពិសេសនេះមិនត្រូវបានគេបង្ហាញថា មានអត្ថិភាពឡើយ ។

## II. ច្បាប់នៅជាធរមាន

4. មាត្រា ៥.៤ នៃសេចក្ដីណែនាំអនុវត្តការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ(វិសោធនកម្មលើកទី៣ នៅថ្ងៃទី២៧ ខែ តុលា ឆ្នាំ ២០០៨) (ហៅថា "**សេចក្ដីណែនាំអនុវត្ត**") ចែងថា:

"តាមការស្នើសុំរបស់ភាគីចូលរួម សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះដែលពាក់ព័ន្ធអាចបង្កើនចំនួនសន្លឹករបស់ឯកសារនៅក្នុងកាលៈទេសៈពិសេស ។

## III. ពុំមាន "កាលៈទេសៈពិសេស"

5. ក.ស.ព អះអាងថា សំណើរបស់ខ្លួនបំពេញហួសពីបទដ្ឋាននៃ "កាលៈទេសៈពិសេស" ទៅទៀត ។ មេធាវីការពារក្ដីជំទាស់ទៅនឹងការអះអាងបែបនេះ ដោយឈរលើអំណះអំណាងខាងក្រោម:

---

[1] ឯកសារលេខ D-130 ។

[2] ឯកសារលេខ D-130/1 ។

## ៣.១ ភាពស្មុគស្មាញនៃបញ្ហាដែលត្រូវបានលើក

6. ក.ស.ព បានទាញហេតុផលថា បញ្ហាដែលលើកឡើងដោយមេធាវីការពារក្តី គឺ "ជាបញ្ហាស្មុគស្មាញ ហើយតម្រូវឱ្យមានការវិភាគលើបទបញ្ញត្តិច្បាប់ និង យុត្តិសាស្ត្រ ចាប់តាំងពីសង្គ្រាមលោកលើកទី២" ហើយ បង្ហាញពីភាពចាំបាច់នៃការយោងទៅលើច្បាប់កម្ពុជាជាច្រើនទសវត្ស។ សំខាន់ជាងនេះទៅទៀត ក.ស.ព អះអាងថា ខ្លួនមានបំណងផ្តល់ការស្នង់មតិទៅលើអត្ថបទដែលសរសេរដោយអ្នកប្រវត្តិវិទូ ទាក់ទងនឹងប្រធានបទនេះ[3] ។

7. មេធាវីការពារក្តីសូមលើកឡើងថា: មេធាវីការពារក្តីដាក់សារណារបស់ខ្លួនក្នុងរង្វង់ ១៥ សន្លឹក ដែលតម្រូវតែប៉ុណ្ណោះ ហើយបានផ្តល់នូវទិដ្ឋភាពទូទៅនៃបទដ្ឋានច្បាប់កម្ពុជាដែលពាក់ព័ន្ធការអនុវត្តនៅតុលាការដទៃទៀត, ច្បាប់អន្តរជាតិដែលនៅជាធរមាន និង បានយោងទៅលើអត្ថបទនានាដែលសរសេរដោយអ្នកប្រវត្តិវិទូ ។

8. បន្ថែមពីលើនេះ ក.ស.ព ខកខានមិនបានកំណត់នូវលក្ខណៈពិសេសណាមួយ ដែលបង្កើតជាទឡ្ហីករណ៍ថា ជា "កាលៈទេសៈពិសេស" នោះឡើយ។

## ៣.២ យុត្តិសាស្ត្រពីតុលាការព្រហ្មទណ្ឌអន្តរជាតិផ្សេងៗ

9. សំណើរបស់ ក.ស.ព បានយោងទៅលើយុត្តិសាស្ត្រពីតុលាការពិសេសសៀរ៉ាឡេអូន (ហៅថា "SCSL") និង តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ហៅថា "ICTY")[4]។ ជាគោលការណ៍ យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិដទៃទៀតអនុញ្ញាតិឱ្យបង្កើនចំនួនសន្លឹកកំណត់នៅក្នុងកាលៈទេសៈមួយចំនួន ដែលជា "ច្បាប់ល្អ ឬ វិចារណញ្ញាណប្រកបដោយគតិបណ្ឌិត"។ ប៉ុន្តែ ករណីដែលលើកឡើងដោយ ក.ស.ព មិនគាំទ្រដល់សំណើរបស់ខ្លួនឡើយ។

10. សំណើរបស់ ក.ស.ព បានយោងទៅលើសេចក្តីសម្រេចចំនួនបួនរបស់តុលាការដទៃទៀត ដែលសំណើសុំបង្កើនចំនួនសន្លឹកកំណត់ត្រូវបានអនុញ្ញាតិ។ ប៉ុន្តែ សំណើទាំងនោះខុសគ្នាយ៉ាងខ្លាំងពីស្ថានភាពនាពេលនេះ ហើយសំរាប់ហេតុផលនេះ មិនអាចអនុវត្តបានចំពោះករណីនេះទេ។

---

[3] សំណើរបស់ ក.ស.ព កថាខណ្ឌ ៣ ។

[4] ICTY និង SCSL អនុវត្តបទដ្ឋាននៃ "កាលៈទេសៈពិសេស" ដូចគ្នា ។ សូមមើលសេចក្តីណែនាំអនុវត្តរបស់ ICTY ស្តីពីកំរាស់នៃសារណា និង ពាក្យសុំ, សំណុំរឿងលេខ. IT/184 Re 2, កថាខណ្ឌ ៧ និង សេចក្តីណែនាំអនុវត្តការដាក់ឯកសាររបស់ SCSL ដែលធ្វើវិសោធនកម្មចុងក្រោយបំផុតនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៥ មាត្រា ៦(ខ) ។

11. ពុំមានករណីណាមួយក្នុងចំណោមករណីដែលលើកឡើងដោយ ក.ស.ព ជាសំណើសុំបង្កើនចំនួនសន្លឹករបស់ចម្លើយតបនោះឡើយ។ ជាញឹកញាប់មានតែភាគីដែលដាក់ឯកសារទេដែលដាក់សំណើសុំបង្កើនចំនួនសន្លឹកកំណត់នេះ។

12. សេចក្តីសម្រេចរបស់តុលាកាពិសេសសៀរ៉ាឡេអូននៅក្នុងរឿងក្តីប្រឆាំងនឹង Brima និងអ្នកផ្សេងទៀត[5] អយ្យការស្នើសុំអង្គជំនុំជម្រះសាលាឧទ្ធរណ៍ឱ្យបង្កើនចំនួនសន្លឹកកំណត់សម្រាប់សារណាបណ្តឹងឧទ្ធរណ៍រួមគ្នាប្រឆាំងនឹងជនជាប់ចោទបីនាក់។ ទឡ្ហីករណ៍គឺថា ព្រះរាជអាជ្ញានៅក្នុងរឿងក្តីនោះមានជម្រើសមួយ គឺខ្លួនអាចដាក់សារណាបណ្តឹងឧទ្ធរណ៍រួមគ្នា ដែលមានកម្រាស់ ១៧០ សន្លឹក ឬ អាចដាក់សារណាបណ្តឹងឧទ្ធរណ៍បីដាច់ដោយឡែកពីគ្នាដែលសារណានីមួយៗកម្រាស់ ១០០ សន្លឹក។ ជំនួសឱ្យការចាត់ចែងបែបនេះ ព្រះរាជអាជ្ញាស្នើសុំបង្កើនចំនួនសន្លឹកកំណត់សម្រាប់សារណារួមគ្នាកម្រាស់ ២៥០ សន្លឹកវិញ ដែលសំណើនេះត្រូវបានអនុញ្ញាត។ ស្របពេលជាមួយគ្នានេះ សំណើរបស់មេធាវីការពារក្តីស្នើសុំបង្កើនចំនួនសន្លឹកកំណត់ក៏ត្រូវបានអនុញ្ញាតិផងដែរ។

13. សេចក្តីសម្រេចរបស់ ICTY នៅក្នុងរឿងក្តីប្រឆាំងនឹង Seselj[6] អង្គជំនុំជម្រះសាលាដំបូងពិចារណាថា "ព្រះរាជអាជ្ញាស្វែងរកនៅក្នុងសំណើរបស់ខ្លួននូវការបង្កើនចំនួនសន្លឹកកំណត់ជាមុនដោយលើកហេតុផលថា ការបង្កើនចំនួនសន្លឹកនេះ គឺចាំបាច់ដើម្បីឆ្លើយតបចំពោះបញ្ហាច្បាប់ស្មុកស្មាញមួយចំនួនដែលលើកឡើងនៅក្នុងពាក្យសុំ ដែលពាក្យសុំនេះទៀតសោតហួសពីចំនួនសន្លឹកកំណត់ធម្មតាដែលអនុញ្ញាតិដោយអង្គជំនុំជម្រះនេះទៅទៀត"[7]។ ស្រដៀងគ្នានេះ សេចក្តីសម្រេចនៅក្នុងរឿងក្តីប្រឆាំងនឹង Jovica Stanisic[8] អង្គជំនុំជម្រះសាលាដំបូងរបស់ ICTY អនុញ្ញាតិឱ្យមេធាវីការពារក្តីបង្កើនចំនួនសន្លឹកកំណត់ ដោយយល់ឃើញថា: "អនុលោមតាមពាក្យសុំរបស់

[5] រឿងក្តីរវាងរដ្ឋអាជ្ញាតទល់ជាមួយ Brima និង អ្នកផ្សេងទៀត.. សេចក្តីសម្រេចលើពាក្យសុំជាបន្ទាន់របស់ព្រះរាជអាជ្ញា ស្នើសុំបង្កើនចំនួនសន្លឹកកំណត់សម្រាប់សារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួន ។ សំណុំរឿងលេខ SCSL-04-16-A-645 ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ។

[6] រឿងក្តីរវាងរដ្ឋអាជ្ញាតទល់ជាមួយ Seselj សេចក្តីសម្រេចលើសំណើរបស់ព្រះរាជអាជ្ញាស្នើសុំបង្កើនចំនួនសន្លឹកឱ្យលើសពី ១០ សន្លឹកកំណត់សម្រាប់ពាក្យសុំ។ សំណុំរឿងលេខ. IT-03-67-PT, ចុះថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០០៤។

[7] សេចក្តីសម្រេចលើករណី Seselj ។

[8] រឿងក្តីរវាងរដ្ឋអាជ្ញាតទល់ជាមួយ Stanisic និង Jovica សេចក្តីសម្រេចទៅលើសំណើរបស់មេធាវីការពារស្នើសុំបង្កើនចំនួនសន្លឹកកំណត់របស់សារណាបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារ, សំណុំរឿងលេខ IT-03-69-PT ថ្ងៃទី៦ ខែធ្នូ ឆ្នាំ២០០៤ ។

ព្រះរាជអាជ្ញា ដែលស្នើសុំ "ការអនុញ្ញាតិដាក់សារណានៅដំណាក់កាលមុនអង្គសេចក្ដីមិនឲ្យលើសពី ១០០ សន្លឹក" ហេតុដូច្នេះ អយ្យការត្រូវបានបង្គាប់ឲ្យដាក់សារណានៅដំណាក់កាលមុនអង្គសេចក្ដីមិនឲ្យលើសពី ១០០ សន្លឹក នោះឡើយ"[9]។ អាស្រ័យហេតុនេះ ព្រះរាជអាជ្ញានៅក្នុងករណីនោះ ត្រូវបានអនុញ្ញាតិឲ្យបង្កើន ៥០ សន្លឹកបន្ថែមទៀត។

14. នៅក្នុងសេចក្ដីសម្រេចប្រឆាំងនឹង Milutinovic ក៏ពុំមានការគាំទ្រដែរ[10]។ ជាបឋម ក៏ដូចជាសេចក្ដីសម្រេចបីផ្សេងទៀតដែរ សេចក្ដីសម្រេចនេះមិនបានលើកឡើងអំពីមូលហេតុធ្វើសំណើបែបនេះឡើយ ហើយទី២ សំណើនេះ គឺជាការស្នើសុំការបង្កើនចំនួនសន្លឹកកំណត់របស់សារណានៅដំណាក់កាលមុខអង្គសេចក្ដី ដែលជាឯកសារមានចរិតលក្ខណៈខុសគ្នាទាំងស្រុង ជាជាងចម្លើយតបដែលមានចរិតលក្ខណៈដាក់កម្រិតដែល ក.ស.ព មានបំណងដាក់នោះទេ។

15. សម្រាប់មូលហេតុទាំងនេះ យុត្តិសាស្ត្រដែលលើកឡើងដោយ ក.ស.ព មិនគាំទ្រដល់សំណើរបស់ខ្លួនសម្រាប់បង្កើនចំនួនសន្លឹកកំណត់នោះឡើយ។

16. ក.ស.ព ខកខានមិនបានបង្ហាញពីអត្ថិភាពនៃ "កាលៈទេសៈពិសេស" ដែលតម្រូវដោយមាត្រា ៥.៤ នៃសេចក្ដីណែនាំអនុវត្ត។

## IV. ការពន្យារពេលមិនត្រឹមត្រូវ

17. លើសពីនេះទៅទៀត វាហាក់ដូចជាថា សំណើរបស់ ក.ស.ព អាចបណ្ដាលឲ្យមានការយឺតយ៉ាវដោយហេតុថា ក.ស.ព បានបញ្ជាក់រួចមកហើយពីចេតនារបស់ខ្លួន ក្នុងការដាក់ចម្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្ដីស្នើសុំឲ្យច្រានចោលភស្តុតាងដែលបានមកនៅមុន ឬ នៅថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០០៩[11] ដែលមានរយៈពេលជាងពីរខែកន្លះមកហើយ បន្ទាប់ពីមេធាវីការពារក្ដីបានដាក់សំណើរបស់ខ្លួនរួចមក។

---

[9] សេចក្ដីសម្រេចលើរឿងក្ដី Stanisic នៅទំព័រ២ (Footnote ត្រូវបានលុបចោល)។

[10] រឿងក្ដីរវាងរដ្ឋអាជ្ញាតទល់ជាមួយ Milutinovic សេចក្ដីសម្រេចទៅលើសំណើរបស់អយ្យការស្នើសុំបង្កើនចំនួនសន្លឹកកំណត់ ករណីលេខ. IT-99-37-PT, ថ្ងៃទី៣ ខែមថុនា ឆ្នាំ២០០៤។

[11] សំណើរបស់ ក.ស.ព កថាខណ្ឌ ២ ។

18. សារណាដែលដាក់នៅចំពោះមុខ ក.ស.ច.ស មិនត្រូវបានរាប់បញ្ចូលនៅក្នុងបទប្បញ្ញត្តិស្តីពីការកំណត់កាលបរិច្ឆេទនៅក្នុងសេចក្តីណែនាំអនុវត្ត[12] ដែលមានន័យថា ការកំណត់កាលបរិច្ឆេទមិនអនុវត្តចំពោះការឆ្លើយតបរបស់សហព្រះរាជអាជ្ញា និងការឆ្លើយតបរបស់មេធាវីការពារនោះទេ។ ប៉ុន្តែ ការចំណាយពេលវេលាដល់ទៅបីខែ សម្រាប់ការរៀបចំចម្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តី ហាក់ដូចជាមានរយៈពេលយូរអង្វែងមិនសមហេតុផលទាល់តែសោះសម្រាប់មេធាវីការពារក្តីនោះ ហើយអាចជាមូលហេតុសម្រាប់ការពន្យារពេលមិនត្រឹមត្រូវ។ មេធាវីការពារក្តីសូមលើកឡើងថា ប្រសិនបើ ក.ស.ព ជាប់កាតព្វកិច្ចទៅនឹងការកម្រិតចំនួនសន្លឹកដូចដែលបានកំណត់ដោយសេចក្តីណែនាំអនុវត្ត នោះ ក.ស.ព គួរតែស្ថិតនៅក្នុងជំហរមួយឆ្លើយតបឱ្យបានកាន់តែឆាប់រហ័ស ដើម្បីធានាថានឹងមិនបណ្តាលឱ្យមានការយឺតយ៉ាវដល់ការវិនិច្ឆ័យក្តីលើបញ្ហាដែលបានលើកឡើងនោះទេ។

## IV. ក.ស.ព អនុវត្តបទដ្ឋានមិនត្រឹមត្រូវ

19. ការលើកឡើងថា "ការបង្កើនចំនួនសន្លឹកនេះ មិនត្រូវប៉ះពាល់ដល់សិទ្ធិរបស់ជនត្រូវចោទនោះទេ ហើយជាផលប្រយោជន៍នៃយុត្តិធម៌" គឺជាការយល់ខុស ដោយហេតុថា វាមិនមែនជាបទដ្ឋានសមស្របប្រឆាំងទៅនឹងសំណើ ដែលគួរត្រូវបានថ្លឹងថ្លែងនោះទេ។ បទដ្ឋាននេះគឺជា "កាលៈទេសៈពិសេស" ដែល ក.ស.ព ត្រូវផ្តល់អំណះអំណាង គឺមិនមែនមេធាវីការពារក្តីជាអ្នកបង្ហាញឱ្យឃើញថា វាប៉ះពាល់ដល់សិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌របស់ជនត្រូវចោទនោះទេ។

20. បើទោះបីជាថា ការប្រកាន់ខ្ជាប់ទៅនឹងបទប្បញ្ញត្តិនៃសេចក្តីណែនាំអនុវត្ត គឺជាការពាក់ព័ន្ធទៅនឹងមេធាវីការពារក្តី, ជាពិសេស ដោយសារថា មេធាវីការពារក្តីមិនបានស្នើសុំឱ្យមានការបង្កើនចំនួនសន្លឹកនោះទេ។ មេធាវីការពារក្តីបានដាក់ជូននូវទឡ្ហីករណ៍របស់ខ្លួននៅក្នុងវង្វង់ចំនួន ១៥ សន្លឹក ដូចដែលបានកំណត់។ ដោយសារតែវាជាសំណើរបស់មេធាវីការពារក្តី នោះមេធាវីការពារក្តីនឹងត្រូវជាអ្នកបង្ហាញពីករណីរបស់ខ្លួននេះ។ ក.ស.ព គួរតែច្រានចោលទឡ្ហីករណ៍នេះនៅក្នុងចំនួនសន្លឹកដែលបានកំណត់។

[12] មាត្រា៨ នៃសេចក្តីណែនាំអនុវត្តអំពីការដាក់ឯកសារ អនុវត្តតែចំពោះ "អង្គជំនុំជម្រះ" ប៉ុណ្ណោះ គឺមិនអនុវត្តចំពោះការិយាល័យសហចៅក្រមស៊ើបអង្កេតនោះទេ។

21. មូលហេតុនៅពីខាងក្រោយការកម្រិតចំនួនសន្លឹកនេះ គឺដើម្បីទប់ស្កាត់ភាគីទាំងឡាយកុំឱ្យលើកឡើងនូវទឡ្ហីករណ៍ដដែលម្ដងទៀត និងចាប់បង្ខំពួកគេឱ្យលើកឡើងនូវទឡ្ហីករណ៍ដែលខ្លីហើយច្បាស់។ នៅក្នុងរឿងក្ដីប្រឆាំងនឹង Kordic និង Cerkez អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃ ICTY បានពិចារណាដូចខាងក្រោម នៅក្នុងការសម្រេចទៅលើសំណើសុំឱ្យបង្កើនចំនួនសន្លឹក:[13]

> "វានឹងត្រូវបានទទួលស្គាល់ដោយអ្នក ដែលមានបទពិសោធនៅក្នុងការសរសេរសារណាជាលាយលក្ខអក្សរដែលវាត្រូវចំណាយពេលយ៉ាងច្រើនក្នុងការសរសេរសារណាទាំងនោះឱ្យខ្លីហើយច្បាស់ជាជាងការអនុញ្ញាតឱ្យសរសេរសារណាទាំងនោះ ដែលសម្បូរដោយពាក្យសំដីឥតប្រយោជន៍។ វាត្រូវមានកំរិតនៃជំនាញក្នុងការសរសេរផងដែរ ហើយនេះមិនមែនសុទ្ធតែធ្វើបានដូចគ្នានោះទេ"

## V. សេចក្ដីសន្និដ្ឋាន

22. សម្រាប់ហេតុផលដែលបានលើកឡើងខាងលើ មេធាវីការពារក្ដីសំណូមពរឱ្យការិយាល័យសហចៅក្រមស៊ើបអង្កេតច្រានចោលសំណើរបស់សហព្រះរាជអាជ្ញា។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៨។

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**ផាត់ ពៅសៀង**
សហមេធាវី

**Ms. Diana ELLIS, DC**
សហមេធាវី

[13] រដ្ឋអាជ្ញា តទល់នឹង Kordic និង Cerkez ។ សេចក្ដីសម្រេចអនុញ្ញាតឱ្យសារណារបស់ដើមបណ្ដឹងឧទ្ធរណ៍មានចំនួនសន្លឹកលើសពីការកម្រិត ដែលកំណត់ដោយសេចក្ដីណែនាំអនុវត្តអំពីកំរាស់នៃសារណា និងពាក្យសុំ។ រឿងក្ដីលេខ IT-95-14/2